# កំណត់សំគាល់ ផ្នែកច្បាប់
# ស្តីពី
# ពិន័យអន្តរការណ៍ ចំពោះអំពើល្មើសទៅនិងច្បាប់ស្តីពី គណនេយ្យ និង សវនកម្ម សម្រាប់ សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល( NGOs )

## ប្រវត្តិ

ព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៦ ប្រកាសឲ្យប្រើច្បាប់ស្តីពី គណនេយ្យ និងសវនកម្ម ។

អនុក្រឹត្យលេខ ៧៩ អនក្រ.បក ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនិងច្បាប់ស្តីពី គណនេយ្យ និសវនកម្ម ចុះថ្ងៃទី ០១ មិថុនា ២០២០។

ប្រកាសលេខ ៥៦៣ សហវ.ប្រក ស្តីពី កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុអោយរងសវនកម្មឯករាជ្យ ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ១០ កក្កដា ២០២០។

## លក្ខខណ្ឌនៃការអនុវត្តកាតព្វកិច្ចសវនកម្មឯករាជ្យ

អង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគណនេយ្យនីមួយៗ របស់ខ្លួនឱ្យរងសវនកម្មឯករាជ្យ ប្រសិនបើអង្គភាពមិនស្វែងរកប្រាក់ចំណេញស្ថិតក្នុងលក្ខណវិនិច្ឆ័យទាំងពីរខាង ក្រោម ៖

- ចំណាយសរុបប្រចាំឆ្នាំ លើសពី ២.០០០.០០០.០០០(ពីរប៊ីលាន រៀល) និង
- មានចំនួនកម្មករនិយោជិតបម្រើការងារចាប់ពី ២០(ម្ភៃ) នាក់ ឡើងទៅ ដោយយោងទៅតាមចំនួនកម្មករនិយោជិតមធ្យមភាគ ដែលមានក្នុងឆ្នាំ។

អង្គភាពមិនស្វែងរកប្រាក់ចំណេញទាំងឡាយណាដែលមិនស្ថិតក្នុងលក្ខណវិនិច្ឆ័យទាំងពីរខាងលើ អាចដាក់ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យរងសវនកម្មឯករាជ្យ ដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត។[1]

## ភាតព្វកិច្ចរបស់បុគ្គលជាប់ភាតព្វកិច្ច

ការងារធ្វើសវនកម្មឯករាជ្យ និងការបោះផ្សាយមតិសវនកម្មឯករាជ្យលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវបញ្ចប់ ឱ្យបានរួចរាល់មិនឱ្យហួសពីរយៈពេល ៦(ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។ ក្នុងករណីមិនអាច អនុវត្តតាមពេលកំណត់នេះ បុគ្គលជាប់កាតព្វកិច្ចអាចស្នើសុំពន្យារពេលមក និយ័តករគណនេយ្យនិងសវនកម្ម (ន.គ.ស.)ដោយមានបញ្ជាក់ពីមូលហេតុ សមស្រប។

បុគ្គលជាប់កាតព្វកិច្ចត្រូវផ្ញើរបាយការណ៍ហិរញ្ញវត្ថុដែលរងសវនកម្មឯករាជ្យរួច និងរបាយកាណ៍សវនកម្មឯករាជ្យមក និយ័តករគណនេយ្យនិងសវនកម្ម (ន.គ.ស.)មិនឱ្យហួសពីរយៈពេល ៦ (ប្រាំមួយ ខែ ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទ បិទបញ្ជីគណនេយ្យ។

ការធ្វើសវនកម្មឯករាជ្យ លើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគណនេយ្យ ឆ្នាំ ២០២០ ត្រូវបានកំណត់ ថាជាការធ្វើសវនកម្មឯករាជ្យ ឆ្នាំទី១។ សវនករមិនត្រូវផ្តល់សេវាសវនកម្មជូន សហគ្រាស ឬ អង្គភាពមិនស្វែងរកប្រាក់ចំណេញណាមួយលើសពី ០៥(ប្រាំ)ឆ្នាំ បន្តបន្ទាប់គ្នាឡើយ។

បុគ្គលជាប់កាតព្វកិច្ច ត្រូវបង់កម្រៃសេវារក្សាទុករបាយការណ៍ហិរញ្ញវត្ថុ ដែលត្រូវកំណត់ដោយប្រកាសរបស់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[2]

## ទោសប្បញ្ញត្តិ

ដោយមិនទាន់គិតពីទណ្ឌកម្មផ្សេងទៀតដូចមានចែងក្នុងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងលិខិតបទដ្ឋាន ក្នុងវិស័យគណនេយ្យនិងសវនកម្មជាធរមានក្នុងព្រះរាជាណាចក្រកម្ពុជា អង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវទទួលរងការពិន័យអន្តរការណ៍ពីនិយ័តករគណនេយ្យនិងសវនកម្ម(ន.គ.ស) ដូចមានចែងក្នុងអនុក្រឹត្យលេខ ៧៩ អនក្រ បក ចុះថ្ងៃទី ១ ខែ មិថុនា ឆ្នាំ២០២០ និងពិន័យអន្តរការណ៍ជាប្រាក់ចំពោះបទល្មើសដូចខាងក្រោម៖

ក-ការប្រើការិយបរិច្ឆេទគណនយ្យខុសពីច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ដោយគ្មានការ អនុញ្ញាត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ៨០០.០០០ (ប្រាំបីសែន)រៀល។

[1] ប្រកា ៦ ប្រកាសលេខ ៥៦៣ សហវ.ប្រក ស្តីពី កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុអោយរងសវនកម្មឯករាជ្យ

[2] ប្រកា ៩-១២ ប្រកាសលេខ ៥៦៣ សហវ.ប្រក ស្តីពី កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុអោយរងសវនកម្មឯករាជ្យ

ខ-ការមិនប្រើភាសាខ្មែរនៅក្នុងបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ៨០០ ០០០ (ប្រាំបីសែន) រៀល។

គ-ការប្រើរូបិយប័ណ្ណនៅក្នុងបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ក្រៅពីប្រាក់រៀលដោយគ្មានការអនុញ្ញាត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ៨០០, ០០០ (ប្រាំបីសែន)រៀល។

ឃ-ការមិនដាក់ ឬភាពយឺតយ៉ាវក្នុងដាក់របាយការណ៍ហិរញ្ញវត្ថុ មកនិយ័តករគណនេយ្យនិងសវនកម្ម (ន.គ.ស.) តាមពេលវេលាកំណត់ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១,២០០.០០០ (មួយលានពីរសែន)រៀល។

ង-ការមិនកាន់បញ្ជីគណនេយ្យ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ៦,៤០០.០០០(ប្រាំមួយលានបួនសែន)រៀល។

ច-ការមិនរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន ត្រូវពិន័យអន្តរការណ៍ ជាប្រាក់ ៦. ៤០០, ០០០ ( ប្រាំមួយលានបួនសែន)រៀល។

ឆ-ការខកខានមិនដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១.៦០០.០០០ (មួយលានប្រាំមួយសែន) រៀល។

ជ-ការមិនប្រើរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន សម្រាប់ការបំពេញកាតព្វកិច្ច សារពើពន្ធ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ៤.៨០០០០០(បួនលានប្រាំបីសែន)រៀល។

ឈ-ការមិនរក្សាទុកឯកសារគណនេយ្យតាមច្បាប់កំណត់ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ៨.០០០ ០០០ (ប្រាំបីលាន)រៀល។[3]

## **សេចក្តីបញ្ជាក់**

អត្ថបទបង្ហាញនេះ បានធ្វើឡើងដោយមានការឧបត្ថម្ភសប្បុរសធម៌ពីប្រជាពលរដ្ឋអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)។ មាតិកានៃបទបង្ហាញនេះជាការទទួលខុសត្រូវរបស់អង្គការ ជំនួយ ផ្នែកច្បាប់ នៃកម្ពុជា និងមិនឆ្លុះបញ្ចាំងជាចាំបាច់ពីទស្សនៈរបស់ FHI 360 ឬ USAID ឬរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ។

---

[3] មាត្រា ៦ អនុក្រឹត្យលេខ ៧៩ អនក្រ.បក ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនិងច្បាប់ស្តីពី គណនេយ្យ និសវនកម្ម